## សន្ទរកថារបស់ដៃគូអភិវឌ្ឍន៍ ស្តីពីកិច្ចគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនដែលងាយរងគ្រោះ

## ថ្លែងដោយលោក Jean-Peirre De Margerie

## ប្រធានកម្មវិធីស្បៀងអាហារពិភពលោកប្រចាំប្រទេសកម្ពុជា និងជាតំណាងដៃគូអភិវឌ្ឍន៍

## ក្នុងកិច្ចប្រជុំលើកទី១៨នៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១

- សូមគោរពឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សូមគោរពឯកឧត្តម លោកជំទាវ អស់លោក លោកស្រី

ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ដោយបានឡើងថ្លែងសន្ទរកថាក្នុងប្រធានបទស្តីពីការគាំពារសង្គម នៅក្នុងវេទិកានេះជាថ្មីម្តងទៀត ក្នុងនាមតំណាងឱ្យដៃគូអភិវឌ្ឍន៍។ ក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំសូមសម្តែងនូវការស្វាគមន៍ និងអបអរសាទរដល់ការអនុម័តរបស់រាជរដ្ឋាភិបាលលើយុទ្ធសាស្ត្រជាតិគាំពារសង្គម កាលពីថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១១ និងសូមសម្តែងនូវការកោតសរសើរដល់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី និងឯកឧត្តម ងី ច័ន្ទផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដែលមានឆន្ទៈខ្ពស់ និងផ្តល់ការគាំទ្រយ៉ាងខ្លាំងដល់ការគាំពារសង្គម។ សូមសម្តែងនូវការកោតសរសើរដល់ការរៀបចំ និងប្រឹក្សាយោបល់យ៉ាងច្រើនក្នុងការរៀបចំបង្កើតយុទ្ធសាស្ត្រនេះ ក្រោមការដឹកនាំដ៏មានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាល និងកិច្ចសហប្រតិបត្តការដ៏ល្អរវាងរដ្ឋាភិបាលជាមួយនឹងដៃគូអភិវឌ្ឍន៍។ យើងមានជំនឿជឿជាក់យ៉ាងមុតមាំថា ការអនុម័តជាផ្លូវការ និងការអនុវត្តជាបន្តបន្ទាប់នូវយុទ្ធសាស្ត្រនេះ នឹងក្លាយជាមូលដ្ឋានគ្រឹះដ៏សំខាន់មួយក្នុងកិច្ចដំណើរការសម្រាប់ការពន្លឿនដើម្បីឆ្ពោះទៅសម្រេចបាននូវចំណុចគោលដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សនៃប្រទេសកម្ពុជា។

ដូចបានកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រជាតិគាំពារសង្គមនឹងមានអភិក្រមបីសំខាន់ គឺ: ១-) ដើម្បីគាំពារអ្នកក្រីក្រ និងជនដែលងាយរងគ្រោះជាងគេក្នុងការទប់ទល់នឹងគ្រោះអាសន្ននានា ២-) ការពារជនក្រីក្រ និងជនងាយរងគ្រោះ ឱ្យជៀសផុតពីការប្រើប្រាស់យន្តការដែលមានលក្ខណៈអវិជ្ជមាន ក្នុងការដោះស្រាយបញ្ហាគ្រោះអាសន្ន ដូចជាបញ្ឈប់កូនមិនឱ្យទៅសាលារៀន ឬក៏បន្ថយម្ហូបអាហារជាដើម និង៣-) ដើម្បីលើកកម្ពស់ការលូតលាស់ផ្នែក សេដ្ឋកិច្ច និងជីវភាពរស់នៅដែលមានលក្ខណៈល្អប្រសើរ តាមរយៈការកែលំអមូលធនមនុស្ស។ ពាក់ព័ន្ធនឹងបញ្ហានេះ ដៃគូអភិវឌ្ឍមានសេចក្តីរីករាយក្នុងការតម្រង់ការគាំទ្ររបស់ខ្លួនទៅនឹងអាទិភាពនានា ដែលបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងយុទ្ធសាស្ត្រជាតិគាំពារសង្គម សម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ ដែលការគាំពារសង្គមនេះ គឺជាគោលនយោបាយដ៏សំខាន់មួយបម្រើឱ្យយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមដោយមិនរើសអើងសម្រាប់ប្រទេសកម្ពុជា។

ឆ្នាំ២០១០ បានបង្ហាញឱ្យឃើញនូវការលូតលាស់ត្រឡប់មកវិញគួរឱ្យកត់សម្គាល់លើផ្នែកសេដ្ឋកិច្ច បន្ទាប់ពីមានការថយចុះនៅក្នុងឆ្នាំ២០០៩ ព្រមទាំងវឌ្ឍនភាពនៃការកាត់បន្ថយភាពក្រីក្រផងដែរ។ សូមអបអរសាទរ ដល់រាជរដ្ឋាភិបាលចំពោះវឌ្ឍនភាពទាំងនេះ។ ក្រៅពីនេះ របកគំហើញជាបឋមនៃការសិក្សាក្នុងឆ្នាំ២០១០ ស្តីពីសុខភាពប្រជាសាស្ត្រនៃប្រទេសកម្ពុជា ក៏បានបង្ហាញឱ្យឃើញផងដែរអំពីភាពប្រសើរឡើងនូវសូចនាករសុខភាពជាច្រើន។ ទោះជាយ៉ាងនេះក្តី ក៏ការសិក្សានេះបានបង្ហាញឱ្យឃើញនូវភាពនៅទ្រឹងនៃសូចនាករមួយចំនួន ដែលក្នុងនោះរួមមានដូចជា សូចនាករពាក់ព័ន្ធនឹងអាហារូបត្ថម្ភ កម្រិតនៃការខ្វះអាហារូបត្ថម្ភនៅមានកម្រិតខ្ពស់នៅឡើយ ក៏ប៉ុន្តែចំពោះសូចនាករ មួយចំនួនទៀតក៏ត្រូវបានសម្រេចនៅក្នុងកម្រិតខ្ពស់គួរឱ្យកត់សម្គាល់ផងដែរ។ យើងនៅមានកិច្ចការជាច្រើនដែលត្រូវអនុវត្តពីពេលបច្ចុប្បន្ននេះរហូតដល់ឆ្នាំ២០១៥ ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ជាពិសេសគឺការធ្វើឱ្យសម្រេចបាននូវចំណុចដៅក្នុងការកាត់បន្ថយភាពក្រីក្រឱ្យដល់១៩.៥ភាគរយ ដែលមានន័យថា ត្រូវធ្វើឱ្យប្រជាពលរដ្ឋក្រីក្រងាយរងគ្រោះជាងគេចំនួន១.៥លាននាក់ ឱ្យផុតពីភាពក្រីក្រ និងធ្វើឱ្យសម្រេចបាននូវ ចំណុចដៅនៃសូចនាករនៃអាហារូបត្ថម្ភ និងសុខភាព។ ដូចបានឆ្លុះបញ្ចាំងនៅក្នុងយុទ្ធសាស្ត្រជាតិគាំពារសង្គម សំណាញ់សុវត្ថិភាពសង្គមដែលផ្តល់ដល់ក្រុមអ្នកទទួលផលឱ្យបានត្រឹមត្រូវ អាចធ្វើឱ្យសម្រេចបាននូវគោលដៅទាំងនេះ តាមរយៈការផ្តល់នូវកិច្ចគាំពារសង្គមជាមូលដ្ឋាន ការដោះស្រាយនូវតម្រូវការជាមូលដ្ឋានរបស់បនុស្ស និងការ ធានាឱ្យបានថាភាពក្រីក្រជាយថាហេតុនានា នឹងមិនក្លាយទៅជាភាពក្រីក្រដែលមានលក្ខណៈរ៉ាំរ៉ៃ។ យើងសង្ឃឹមថា នឹងមានការឯកភាពគ្នាមួយស្តីពីតម្រូវការដែលត្រូវអភិវឌ្ឍន៍ និងគាំទ្រប្រព័ន្ធសម្រាប់រយៈពេលវែង ដែលមានលក្ខណៈសមស្រប និងមានប្រសិទ្ធិភាពមួយនៃកិច្ចគាំពារសង្គមនៅក្នុងប្រទេសកម្ពុជា ដើម្បីធានាឱ្យបានថា ផលប៉ះពាល់នៃកលិបុតម៉ាក្រូសេដ្ឋកិច្ចនានាដែលអាចកើតឡើងនាថ្ងៃអនាគត (ដូចជាការឡើងចុះនៃតម្លៃម្ហូបអាហារ និងប្រេងឥន្ធនៈ) គ្រោះធម្មជាតិ (ដែលអាចកើតឡើងដោយសារបម្រែបម្រួលអាកាសធាតុ) និងគ្រោះភ័យនានា ដែលរវាចកើតមានឡើងក្នុងលក្ខណៈគ្រួសារឬបុគ្គលនីមួយៗ (ដូចជាការបាត់បង់សមាជិកគ្រួសារ ឬជម្ងឺធ្ងន់ធ្ងរនានា) នឹងមិនបង្កាក់ ឬធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ផលចំណេញផ្នែកសេដ្ឋកិច្ច និងប៉ះពាល់ដល់សុខមាលភាពសង្គមដែលបានកែលំអ ធ្វើឱ្យមានលក្ខណៈល្អប្រសើរនាពេលបច្ចុប្បន្ននេះ។

ដូចបានកំណត់នៅក្នុងវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ ដែលបានរៀបចំឡើងនាខែមិថុនា ឆ្នាំ២០១០ ដៃគូអភិវឌ្ឍបានមានឆន្ទៈក្នុងការធ្វើការងារក្នុងភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រជាតិគាំពារសង្គមដែលបានអនុម័តនាពេលថ្មីៗនេះ។ ពាក់ព័ន្ធនឹងបញ្ហានេះដៃគូអភិវឌ្ឍន៍ នឹងធ្វើការជាមួយអង្គភាពសម្របសម្រួលកិច្ចគាំពារសង្គមនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដូចជាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម ក្រសួងធនធានទឹកនិងឧតុនិយម

ក្រសួងកិច្ចការនារី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ច ដែលជាស្ថាប័នពាក់ព័ន្ធផ្ទាល់ និងមិនផ្ទាល់នៅក្នុងការគាំពារសង្គម។ ដៃគូរអភិវឌ្ឍ សូមលើកទឹកចិត្តដល់ការរៀបចំបង្កើតមន្ត្រីបង្គោលកម្រិតបច្ចេកទេស និងកម្រិតខ្ពស់ សម្រាប់ការងារកិច្ចគាំពារសង្គមនៅតាមក្រសួងស្ថាប័ននីមួយៗ ដើម្បីធ្វើការសម្របសម្រួលដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព និងដើម្បីធានាថា កិច្ចគាំពារសង្គមត្រូវបានបញ្ជ្រាបយ៉ាងពេញលេញទៅក្នុងគោលនយោបាយតាមវិស័យ និងផែនការប្រតិបត្តិការប្រចាំឆ្នាំរបស់ក្រសួងស្ថាប័ននីមួយៗ។ ដៃគូអភិវឌ្ឍន៍សូមស្វាគមន៍ដល់ការប្រឹក្សាយោបល់នានា ដែលកំពុងត្រូវបានធ្វើឡើងជាមួយ គ.ជ.អ.ប និងក្រុមការងារបណ្តោះអាសន្នស្តីពីកិច្ចគាំពារសង្គម។ ដៃគូអភិវឌ្ឍន៍នឹងគាំទ្រ ដល់ការភ្ជាប់ទំនាក់ទំនង និងការខិតខំប្រឹងប្រែងនានាក្នុងការដាក់បញ្ចូលការរៀបចំនានាជាលក្ខណៈស្ថាប័នទៅក្នុងកិច្ចដំណើរការតាមបែបប្រជាធិបតយ្យនៅថ្នាក់ក្រោមជាតិ។

ដៃគូអភិវឌ្ឍន៍ក៏គាំទ្រទៅលើវិធីសាស្ត្រផ្អែកលើភស្តុតាងជាមូលដ្ឋានក្នុងការពិភាក្សា និងការរៀបចំគោលនយោបាយ ដោយរួមបញ្ចូលទាំងការរៀបចំ តាមរយៈការអនុវត្តសាកល្បងនូវប្រព័ន្ធថ្មីនៃការឧបត្ថម្ភសាច់ប្រាក់ និងកម្មវិធីសំណង់សាធារណៈ (public work) និងតាមរយៈការពិនិត្យឡើងវិញ និងការវាយតម្លៃនៃកម្មវិធីដែលកំពុងដំណើរការ។ឧទាហរណ៍ កិច្ចខិតខំប្រឹងប្រែងកំពុងត្រូវបានធ្វើឡើងក្នុងការរៀបចំអនុវត្តសាកល្បងនូវកម្មវិធីសាច់ប្រាក់មួយ ដើម្បីដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភ និងកម្មវិធីសំណង់សាធារណៈជាតិ និងការវាយតម្លៃផលប៉ះពាល់នៃការផ្តល់អាហារូបករណ៍ក្នុងលក្ខណៈជាការផ្តល់អាហារ និងការផ្តល់អាហារូបកណ៍ក្នុងលក្ខណៈជាការផ្តល់សាច់ប្រាក់ និងការវាយតម្លៃមួយ ដើម្បីសិក្សាលើកិច្ចដំណើរការនិងលទ្ធផលនានានៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ របស់ក្រសួងផែនការ។ យើងមានការសង្ឃឹមថា មេរៀនដែលទទួលបានពីការសិក្សាវាយតម្លៃទាំងនេះ នឹងជួយសម្របសម្រួលដល់វិធីសាស្ត្រផ្អែកតាមភស្តុតាងជាមូលដ្ឋានសម្រាប់ការពង្រីក និងធ្វើសុខដុមនីយកម្មនៃកម្មវិធីគាំពារសង្គម។ ការគាំទ្ររបស់ដៃគូអភិវឌ្ឍ គឺការកំណត់នូវគំនិតផ្តួចផ្តើមបែបនេះបន្ថែមទៀតនៅក្នុងមូលនិធិរៃអង្គាស (Trust Fund) របស់ធនាគារពិភពលោកនិងទីភ្នាក់អូស្ត្រាលីដើម្បីអភិវឌ្ឍន៍ក្របខណ្ឌជំនួយអភិវឌ្ឍន៍របស់រង្គការសហប្រជាជាតិឆ្នាំ២០១១-២០១៥ និងការគាំទ្រជាលក្ខណៈទ្វេភាគីផ្សេងទៀត។ ដៃគូអភិវឌ្ឍមានគោលជំហររួចជាស្រេចក្នុងការជំរុញយន្តការនានាដែលនឹងគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធមួយ ដែលមានការច្របាច់បញ្ចូលនូវកិច្ចគាំពារសង្គមដូចជាការប្រើប្រាស់ឱ្យបានទូលំទូលាយនូវនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលជាឧបករណ៍គោលដៅរួម។ ពាក់ព័ន្ធនឹងបញ្ហានេះ ការគ្របដណ្តប់ទូទាំងប្រទេស និងនិរន្តរភាពនៃការផ្តល់ហិរញ្ញប្បទានសម្រាប់ការធ្វើបច្ចុប្បន្នភាពទិន្នន័យជាប្រចាំរបស់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺជាចំណុចសំខាន់ក្នុងការធ្វើឱ្យសម្រេចបាននូវគោលបំណងរួមនេះ។

ដូចបានបញ្ជាក់នៅក្នុងវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើទី៣ និងវេទិកានៃគណៈកម្មាធិការសម្របសម្រួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍លើកទី១៧ ដៃគូអភិវឌ្ឍន៍យល់ឃើញថា និរន្តរភាពផ្នែកហិរញ្ញ

វត្ត គឺជាផ្នែកមួយសំខាន់សម្រាប់ការអនុវត្តប្រកបដោយជោគជ័យនៃប្រព័ន្ធជាតិមួយសម្រាប់កិច្ចគាំពារសង្គម។ ពាក់ព័ន្ធនឹងអាទិភាពនៃកិច្ចការនេះ ដៃគូអភិវឌ្ឍន៍នានានឹងផ្តល់ការគាំទ្រលើយន្តការហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ និងរដ្ឋាភិបាលនៅក្នុងកម្រិតខ្ពស់មួយ និងគាំទ្រគណៈកម្មាធិការដឹកនាំ ដែលប្រើប្រាស់វិធីសាស្ត្រគ្រប់គ្រងទូទាំងកម្មវិធី ដែលអាចសម្របសម្រួលនូវការផ្តល់ធនធានបានគ្រប់គ្រាន់សម្រាប់ដំណាក់កាលនៃការចាប់ផ្តើមអនុវត្ត។ សម្រាប់រយៈយូរអង្វែង ការរៀបចំបែបនេះ អាចផ្តល់ការណែនាំដល់កិច្ចដំណើរការនៃការផ្ទេរពីដៃគូអភិវឌ្ឍន៍ទៅរដ្ឋាភិបាលនូវការផ្តល់ហិរញ្ញប្បទាន ផ្អែកតាមភស្តុតាងដ៏រឹងមាំនៃផលប៉ះពាល់របស់កម្មវិធី និងប្រសិទ្ធភាពផ្អែកតម្លៃរបស់កម្មវិធី។ សកម្មភាពនានាអាចរួមបញ្ចូលនូវកិច្ចដំណើរការនៃការពិនិត្យឡើងវិញនូវការចំណាយសាធារណៈ និងការសិក្សាវាយតម្លៃ លើការប្រើប្រាស់ថវិកាដែលបានដាក់បញ្ចូលគ្នា។ ចំពោះបញ្ហានេះ ដៃគូអភិវឌ្ឍន៍សូមស្វាគមន៍ដល់ការគណនាតម្លៃ ប៉ាន់ស្មាននៃកម្មវិធីសាកល្បងនានា និងការពង្រីកជម្រើសផ្សេងៗ ទៀតសម្រាប់កម្មវិធីដែលមានស្រាប់ ដូចបានកំណត់ នៅក្នុងតារាងទី៧នៃយុទ្ធសាស្ត្រស្តីពីកិច្ចគាំពារសង្គម។ ដៃគូអភិវឌ្ឍន៍មានគោលជំហររួចជាស្រេចក្នុងការគាំទ្រដល់រដ្ឋាភិបាលជាបន្តទៀតក្នុងការគណនាតម្លៃដែលកំពុងដំណើរការសម្រាប់កិច្ចគាំពារសង្គម តាមរយៈការផ្តល់ជំនួយ បច្ចេកទេស និងតាមរយៈការចែករំលែកព័ត៌មាន។

**សំណូមពរសំខាន់ៗនានាសម្រាប់ពេលចំពោះមុខ:**

- ដៃគូអភិវឌ្ឍន៍នឹងសូមស្វាគមន៍ នូវការរៀបរាប់ពន្យល់បន្ថែមអំពីផែនការអនុវត្តនៃយុទ្ធសាស្ត្រស្តីពីកិច្ចគាំពារសង្គម មុនពេលនៃវេទិកាសម្របសម្រួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍លើកក្រោយ ជាពិសេសរួមបញ្ចូលទាំងការរៀបចំនានា និងពេលវេលាដែលត្រូវឱ្យក្រសួងស្ថាប័នជំនាញនានាអាចចូលរួម ហើយថាតើការចូលរួមទាំងនេះ នឹងត្រូវឆ្លុះបញ្ចាំងទៅក្នុងផែនការតាមវិស័យផែនការប្រតិបត្តិការប្រចាំ ឆ្នាំរបស់ក្រសួងស្ថាប័ន និងតាមរយៈការរៀបចំជាលក្ខណៈស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិយ៉ាងដូចម្តេច (រួមទាំងការកំណត់មន្ត្រីបង្គោលទាំងកម្រិតបច្ចេកទេស និងកម្រិតខ្ពស់)។
- ដៃគូអភិវឌ្ឍន៍នឹងសូមស្វាគមន៍ ដល់ការណែនាំលើយន្តការរួមគ្នាមួយ មុនពេលនៃវេទិកាសម្របសម្រួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍លើកក្រោយ ដែលយន្តការនេះនឹងគាំទ្រដល់កិច្ចអភិវឌ្ឍ និងធ្វើសុខដុមនីយកម្មនៃអន្តរាគមន៍ថ្មី និងអន្តរាគមន៍ដែលមានស្រាប់ដែលគាំទ្រដល់កិច្ចគាំពារសង្គម ដោយរួមបញ្ចូលទាំងវិធានការនានា ដែលជាឧបករណ៍គោលដៅរួមមួយ ដែលអាចជួយធ្វើសុខដុមនីយកម្មក្នុងការអនុវត្តកម្មវិធីគាំពារសង្គមនានា។
- ចំពោះបញ្ហាជាអាទិភាព ដៃគូអភិវឌ្ឍន៍ សូមឱ្យមានការស្រាយបំភ្លឺអំពីផែនការជាក់លាក់នានារបស់រដ្ឋាភិបាលសម្រាប់ការរៀបចំបង្កើតក្របខ័ណ្ឌការងារហិរញ្ញប្បទានជាប្រចាំ និងប្រកបដោយនិរន្តរភាព ជាពិសេសគឺពាក់ព័ន្ធទៅនឹងគណៈកម្មាធិការគ្រប់គ្រងមួយ សម្រាប់ការត្រួតពិនិត្យមើលលើយន្តការ និងបញ្ហានៃការរៀបចំថវិកា និងការផ្តល់ហិរញ្ញប្បទាន។ សកម្មភាពជាបឋមរបស់គណៈកម្មាធិការគ្រប់ គ្រងនេះ អាចជាការពិនិត្យឡើងវិញលើថវិកាប៉ាន់ស្មាននៃយុទ្ធសាស្ត្រជាតិស្តីពីកិច្ចគាំពារសង្គម។